អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

# សេចក្តីប្រកាសព័ត៌មានបិទកិច្ចប្រជុំពេញអង្គលើកទី៥ របស់ចៅក្រម និងសហព្រះរាជអាជ្ញា ថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៩

ចាប់ពីថ្ងៃច័ន្ទទី២ ដល់ ថ្ងៃសុក្រទី៦ ខែមីនា ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានរៀបចំកិច្ចប្រជុំពេញអង្គលើកទី៥របស់ខ្លួន នៅសណ្ឋាគារ កាំបូឌីយ៉ាណា នារាជធានីភ្នំពេញ។

កិច្ចប្រជុំពេញអង្គនេះ មានគោលបំណងសំខាន់ដើម្បីពិភាក្សាសំណើវិសោធនកម្មលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា ចំនួន៣០ វិធាន។ វិធាន ចំនួន ២៧ ត្រូវបានអនុម័ត។ ភាគច្រើននៃវិសោធនកម្មទាំងនេះ គឺឆ្លុះបញ្ចាំងពីកិច្ចខំប្រឹងប្រែងជួយសម្រួលឲ្យរលូន ឬការធ្វើឲ្យប្រសើរឡើងនូវបញ្ហាបច្ចេកទេសមួយចំនួនតូចផងដែរ។

វិសោធនកម្មទាំងនេះត្រូវបានរៀបចំក្នុងគោលបំណងបង្កើនប្រសិទ្ធិភាព និងពន្លឿននីតិវិធីចំពោះមុខអង្គជំនុំជម្រះទាំងអស់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ រួមមាន៖

- ការពន្លឿនការផ្តល់នីតិសម្បទាដល់អ្នកស៊ើបអង្កេត
- ការពន្លឿននីតិវិធីសម្រាប់កោះហៅសាក្សី កាលពីមុនមានរយៈពេលអប្បបរមា សម្រាប់ការកោះហៅ និងបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះមានចំនួន៥ថ្ងៃ។
- ការសម្រេចថា ពេលចៅក្រមបម្រុងមានជម្ងឺ ឬពុំអាចចូលរួមក្នុងកិច្ចដំណើរការ នីតិវិធីបាន គឺមិនអាចរារាំងដល់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំ ជម្រះទេ។
- ការបញ្ជាក់ឲ្យច្បាស់អំពីអំណាចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងសាក្សី ឬ ភស្តុតាងបន្ថែម។
- ការដកចេញនូវលក្ខខណ្ឌតម្រូវដែលថាសាលក្រមស្ថាបពរត្រូវចេញក្នុងរយៈ ពេល៩០ថ្ងៃ គិតចាប់ពីថ្ងៃសវនាការចុងក្រោយ ដោយពិចារណាដល់ភាពស្មុគស្មាញ និងទំហំនៃរឿងក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។
- ការបញ្ជាក់ឲ្យច្បាស់ថានៅពេលណាភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបាន តំណាងដោយមេធាវី គឺមេធាវីជាអ្នកត្រូវធ្វើសារណាតាមផ្លូវច្បាប់នៅចំពោះមុខអង្គជំនុំជម្រះ មិនមែនភាគីដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងទេ។ វិសោធនកម្មនេះ ពុំបានកម្រិតសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ ប៉ុន្តែបានកែប្រែរបៀបនៃការអនុវត្តសិទ្ធិទាំងនេះ ដោយហេតុថា នៅចំពោះមុខកិច្ចដំណើរការនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញ

ក្នុងតុលាការកម្ពុជា មានភាគីដើមបណ្តឹងរដ្ឋប្បវេណីច្រើន សន្និកសន្ធាប់ និងថាការជំនុំជម្រះនឹងមិនបញ្ចប់បានលឿនទេ ប្រសិនបើភាគីដើមរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យធ្វើអន្តរាគមន៍នៅគ្រប់រឿងនៅគ្រប់តំណាក់កាលនៃកិច្ចដំណើរការនីតិវិធីទាំងអស់នោះ។

- វិសោធនកម្មទាំងនេះមិនអនុវត្តចំពោះករណីដែលភាគីដើមបណ្តឹងរដ្ឋប្បវេណី កំពុងត្រូវបានសួរ និងពុំរារាំងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការឆ្លើយសំណួរ ដែលអង្គជំនុំជម្រះសួរគាត់នោះទេ។
- ការបញ្ជាក់ឲ្យបានច្បាស់ និងសម្រួលបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះ សាលាកំពូល។ វិសោធនកម្មទាំងនេះ ត្រូវបានធ្វើឡើងនៅមុនពេលអង្គ ជំនុំជម្រះសាលាកំពូលចាប់ផ្តើមបំពេញមុខងាររបស់ខ្លួន។ ការរៀបចំដូច្នេះគឺ ដើម្បីធានាឲ្យបាននូវភាពត្រៀមខ្លួនរួចរាល់ជាមុននៃអង្គជំនុំជម្រះសាលាកំពូល ដើម្បីឲ្យអង្គជំនុំជម្រះនេះអាចគ្រប់គ្រងទំហំនៃសំណុំរឿងរបស់ខ្លួនបាន។

នៅថ្ងៃចុងក្រោយនៃកិច្ចប្រជុំពេញអង្គ ប្រធានស្តីទីនៃការិយាល័យរដ្ឋបាល និងមន្ត្រី ជាន់ខ្ពស់ផ្នែកគ្រប់គ្រងតុលាការ ព្រមទាំងប្រធានអង្គភាពជនរងគ្រោះ បានធ្វើបទឧទ្ទេសនាមត្រួសៗជូនកិច្ចប្រជុំពេញអង្គអំពីបញ្ហាប្រឈមជាច្រើននៃការគ្រប់គ្រងការ ជំនុំជម្រះក្តី ដែលបញ្ហាទាំងនេះបណ្តាលមកពីការចូលរួមពីជនរងគ្រោះដែលមានចំនួនច្រើន នៅក្នុងកិច្ចដំណើរការនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា។ ការចូលរួមរបស់ជនរងគ្រោះគឺជាលក្ខណៈពិសេសមួយនៃកិច្ចដំណើរការនីតិវិធីនៃ អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា។ ការអនុវត្តដែលពាក់ព័ន្ធនឹងការចូលរួមរបស់ ជនរងគ្រោះនេះ កំពុងត្រូវបានឃ្លាំមើលយ៉ាងជិតដិតបំផុត ដោយសាលាក្តីអន្តរជាតិនានា ជាពិសេសគឺតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលមានលក្ខន្តិកៈនិងវិធានស្រដៀង គ្នានឹងវិធានរបស់អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា។ ប្រធានផ្នែកកិច្ចការ សាធារណៈបានធ្វើបទបង្ហាញជូនកិច្ចប្រជុំពេញអង្គអំពីសកម្មភាពចុះផ្សព្វផ្សាយដល់ មូលដ្ឋានរបស់ផ្នែកកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផងដែរ។